**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA
*Kingdom of Wonder*
feel the warmth

**ក្រសួងទេសចរណ៍**

**លេខ** ១១៣ ទក

ថ្ងៃព្រហស្បតិ៍ ៧កើត ខែ កត្ដិក ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ២០២១

# ប្រកាស
# ស្ដីពី
# ការដាក់ឱ្យអនុវត្តវិធានសុវត្ថិភាពទេសចរណ៍
# សម្រាប់អាជីវកម្មក្លឹបកម្សាន្តរាត្រីសាល-ឌីស្កូតែក

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២១/០០៤ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ១៩១ អនក្រ.បក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៤ ស្ដីពីការគ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្ដីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្ដល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

ផ្ទះលេខ៣A ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: +៨៥៥ ២៣ ៨៨៤ ៩៧២ ទូរសារ: +៨៥៥ ២៣ ៨៨៤ ៩៧៤ E-mail: admin@mot.gov.kh Website: www.tourismcambodia.org

- បានឃើញអនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ស្ដីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ស្ដីពីវិធានការរដ្ឋបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- យោងប្រកាសលេខ១៧៦ ប្រក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៤ របស់ក្រសួងទេសចរណ៍ស្ដីពីការផ្ដល់អាជ្ញាបណ្ណទេសចរណ៍ដល់អាជីវកម្មវង្គសាល-ឌីស្កូតែក
- យោងប្រកាសលេខ០៤៥ ប្រក ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ក្រសួងទេសចរណ៍ស្ដីពីការធ្វើប្រតិភូកម្មមុខងារផ្ដល់សេវាទេសចរណ៍ទៅឱ្យរដ្ឋបាលរាជធានីខេត្ត
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងទេសចរណ៍

## សម្រេច

**ប្រការ១**.-

ប្រកាសនេះ មានគោលបំណងដាក់ឱ្យអនុវត្តវិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មក្លឹបកម្សាន្តវង្គសាល-ឌីស្កូតែក ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងលើកកម្ពស់សុវត្ថិភាពទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២**.-

ប្រកាសនេះ មានគោលដៅកំណត់អំពីវិធានសុវត្ថិភាពទេសចរណ៍ដល់អាជីវកម្មក្លឹបកម្សាន្តវង្គសាល-ឌីស្កូតែក។

**ប្រការ៣**.-

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះគ្រប់អាជីវកម្មក្លឹបកម្សាន្តវង្គសាល-ឌីស្កូតែក ក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤**.-

លក្ខខណ្ឌវាយតម្លៃការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មក្លឹបកម្សាន្តវង្គសាល-ឌីស្កូតែកក្នុងដំណាក់កាលការឆ្លងរាលដាលនៃជំងឺឆ្លងកូវីដ-១៩ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធ១ នៃប្រកាសនេះ។

**ប្រការ៥**.-

អាជីវកម្មក្លឹបកម្សាន្តវង្គសាល-ឌីស្កូតែក ដែលអនុវត្តត្រឹមត្រូវតាមវិធានសុវត្ថិភាពទេសចរណ៍ដូចមានកំណត់ក្នុងឧបសម្ព័ន្ធ១ នឹងទទួលបាន "លិខិតបញ្ជាក់ទទួលស្គាល់អាជីវកម្មក្លឹបកម្សាន្តវង្គសាល-ឌីស្កូតែក ដែលអនុវត្តស្របតាមវិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មក្លឹបកម្សាន្តវង្គសាល-ឌីស្កូតែក" ដែលមានគំរូកំណត់ក្នុងឧបសម្ព័ន្ធ២ និងឡាបិលបញ្ជាក់ទទួលស្គាល់អាជីវកម្មក្លឹបកម្សាន្តវង្គសាល-ឌីស្កូតែកសុវត្ថិភាពប្រឆាំងនឹងកូវីដ-១៩ ដែលមានគំរូកំណត់ក្នុងឧបសម្ព័ន្ធ៣ នៃប្រកាសនេះ។

អាជីវកម្មក្លឹបកម្សាន្តវង្គសាល-ឱស្ថតែក ដែលអាចចាត់ទុកថាអនុវត្តត្រឹមត្រូវតាម "វិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មក្លឹបកម្សាន្តវង្គសាល-ឱស្ថតែក" បានលុះត្រាតែ៖

- អាជីវកម្មអនុវត្តបានចាប់ពី៨០%ឡើង នៃពិន្ទុសរុប និង
- បំពេញបានគ្រប់ចំណុចតម្រូវចាំបាច់ទាំងអស់។

**ប្រការ៦**.-

ប្រតិបត្តិករទេសចរណ៍ ដែលមានបំណងប្រកបអាជីវកម្មក្លឹបកម្សាន្តវង្គសាល-ឱស្ថតែក ឬបន្តអាជ្ញាបណ្ណទេសចរណ៍ដែលគ្រប់គ្រងដោយក្រសួងទេសចរណ៍ ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍នៅក្រសួងទេសចរណ៍ ឬតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (តាមរយៈគេហទំព័រទទួលស្គាល់ផ្លូវការដោយក្រសួងទេសចរណ៍) មានក្នុងប្រកាសលេខ១៧៦ ប្រក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៤ របស់ក្រសួងទេសចរណ៍ ស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់អាជីវកម្មវង្គសាល-ឱស្ថតែក។

ប្រតិបត្តិករទេសចរណ៍ ដែលមានបំណងប្រកបអាជីវកម្មក្លឹបកម្សាន្តវង្គសាល-ឱស្ថតែក ឬបន្តអាជ្ញាបណ្ណទេសចរណ៍ដែលគ្រប់គ្រងដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍នៅអង្គភាពច្រកចេញចូលតែមួយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដូចមានកំណត់ក្នុងប្រកាសលេខ០៤៥ ប្រក ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ក្រសួងទេសចរណ៍ស្តីពីការធ្វើប្រតិភូកម្មមុខងារផ្តល់សេវាទេសចរណ៍ទៅឱ្យរដ្ឋបាលរាជធានីខេត្ត។

វិធានសុវត្ថិភាពទេសចរណ៍នេះត្រូវបានដាក់ឱ្យអនុវត្តជាកាតព្វកិច្ច និងជាលក្ខខណ្ឌបន្ថែមក្នុងការស្នើសុំថ្មី ឬបន្តអាជ្ញាបណ្ណទេសចរណ៍។

**ប្រការ៧**.-

អាជីវកម្មក្លឹបកម្សាន្តវង្គសាល-ឱស្ថតែក ដែលបានបិទផ្អាកដោយក្រសួងទេសចរណ៍ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងអំឡុងវិបត្តិកូវីដ-១៩ ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ថ្មី ដែលមានសុពលភាពរយៈពេល១ (មួយ) ឆ្នាំ គិតចាប់ពីថ្ងៃដាក់ពាក្យស្នើសុំបានពេញលេញ ស្របតាមបែបបទ និងនីតិវិធីស្នើសុំអាជ្ញាបណ្ណទេសចរណ៍ថ្មី។

**ប្រការ៨**.-

អាជីវកម្មក្លឹបកម្សាន្តវង្គសាល-ឱស្ថតែក ដែលគ្មានលិខិតបញ្ជាក់ទទួលស្គាល់អាជីវកម្មក្លឹបកម្សាន្តវង្គសាល-ឱស្ថតែក ដែលអនុវត្តស្របតាមវិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មក្លឹបកម្សាន្តវង្គសាល-ឱស្ថតែក និងអាជីវកម្មក្លឹបកម្សាន្តវង្គសាល-ឱស្ថតែក ដែលមិនបានអនុវត្ត ឬអនុវត្តមិនបានត្រឹមត្រូវតាមវិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មក្លឹបកម្សាន្តវង្គសាល-ឱស្ថតែក នឹងក្លាយជាកម្មវត្ថុនៃការព្យួរអាជ្ញាបណ្ណជាបន្ទាន់ ស្របតាមមាត្រា៤៤ កថាខណ្ឌទី២ នៃច្បាប់ស្តីពីទេសចរណ៍។

**ប្រការ៩**.-

ជនណាដែលក្លែងលិខិតបញ្ជាក់ទទួលស្គាល់អាជីវកម្មក្លឹបកម្សាន្តរង្គសាល-ឌីស្កូតែក ដែលអនុវត្តត្រឹមត្រូវតាមវិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មក្លឹបកម្សាន្តរង្គសាល-ឌីស្កូតែក និង/ឬឡាបិល ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១០**.-

វិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មក្លឹបកម្សាន្តរង្គសាល-ឌីស្កូតែកនេះ ត្រូវបានដាក់ឱ្យអនុវត្តក្នុងដំណាក់កាលទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ហើយអាចនឹងបន្តក្នុងដំណាក់កាលបន្តទៀតតាមការចាំបាច់។

**ប្រការ១១**.-

រាល់បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១២**.-

នាយកខុទ្ទកាល័យ អគ្គនាយកគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ អគ្គាធិការ ប្រធាននាយកដ្ឋានគ្រប់គ្រងសេវាកម្សាន្ត និងកីឡាទេសចរណ៍ ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងទេសចរណ៍ ប្រធានមន្ទីរទេសចរណ៍រាជធានីខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**រដ្ឋមន្ត្រី**

**ថោង ខុន**

**<u>កន្លែងទទួល៖</u>**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងសុខាភិបាល
-គណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-សាលារាជធានី ខេត្ត
-សហព័ន្ធទេសចរណ៍កម្ពុជា
-ដូចប្រការ១២
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធ១

## នៃប្រកាសលេខ...១១៣ ប្រ.ក...ចុះថ្ងៃទី...១៧...ខែ...វិច្ឆិកា....ឆ្នាំ២០២១...

## ស្ដីពី

## “ការដាក់ឱ្យអនុវត្តវិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មក្លឹបកម្សាន្តរង្គសាល-ឌីស្កូតែក”

| ល.រ | លក្ខខណ្ឌ | ការត្រួតពិនិត្យ | ពិន្ទុ | |
|---|---|---|---|---|
| **១** | **ការរៀបចំនៅច្រកចូល និងទីតាំងចំណតក្លឹបកម្សាន្តរង្គសាល-ឌីស្កូតែក** | | **ចាំបាច់** | **ជម្រើស** |
| ១.១ | រៀបចំចំណតយានយន្តឱ្យបានត្រឹមត្រូវ និងមានបុគ្គលិក ឬសន្តិសុខប្រចាំការ និងត្រូវពិនិត្យលេខកូដកក់ទុករបស់ភ្ញៀវ មុនអនុញ្ញាតឱ្យចូល (ក្នុងករណីភ្ញៀវកក់ទុកមុន) ។ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ៥* | |
| ១.២ | មានគំនូសសញ្ញាគម្លាតសុវត្ថិភាពនៅច្រកចូល ដោយមានបុគ្គលិកប្រចាំការ វាស់កម្ដៅ បាញ់អាល់កុល ត្រួតពិនិត្យប័ណ្ណចាក់វ៉ាក់សាំងរបស់ភ្ញៀវ ណែនាំភ្ញៀវឱ្យចុះឈ្មោះក្នុងប្រព័ន្ធ QR CODE និងមានម៉ាស៊ីនត្រួតពិនិត្យកម្ដៅ បាញ់អាល់កុល ឬទូសម្លាប់មេរោគដោយស្វ័យប្រវត្តិ និងត្រូវមានកន្លែង ឬតុសន្តិសុខនៅច្រកចូល និងមានកន្លែងធ្វើតេស្តរហ័សកូវីដ-១៩ភ្ញៀវ។ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ៥* | |
| ១.៣ | រៀបចំច្រកចេញ-ចូលអាជីវកម្មក្លឹបកម្សាន្តរង្គសាល-ឌីស្កូតែកផ្សេងគ្នា។ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | | ៥ |
| ១.៤ | មានបិទផ្សាយគោលការណ៍ណែនាំជាទម្រង់ Poster ស្ដីពីវិធានការសុខាភិបាល និងប្រភេទទណ្ឌកម្មចំពោះការប្រព្រឹត្តល្មើសនឹងគោលការណ៍ណែនាំ ស្ដីពីវិធានការការពារជំងឺកូវីដ-១៩ នៅច្រកចូលបរិវេណអាជីវកម្មក្លឹបកម្សាន្តរង្គសាល-ឌីស្កូតែក។ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ៥* | |
| | **សរុប** | **ពិន្ទុធ្វើបាន........** | **១៥** | **៥** |
| **២** | **ការរៀបចំនៅបញ្ជរព័ត៌មាន និងកន្លែងទទួលភ្ញៀវ** | | **ចាំបាច់** | **ជម្រើស** |
| ២.១ | មានគោលការណ៍ណែនាំដល់ផ្នែកសេវាកម្មកក់ត្រូវផ្ដល់ព័ត៌មានជូនភ្ញៀវនៅពេលការកក់គ្រប់ចំនួន ចៀសវាងការរង់ចាំរបស់ភ្ញៀវនៅក្លឹបកម្សាន្តរង្គសាល-ឌីស្កូតែក។ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ៥* | |

| | | | | |
|---|---|---|---|---|
| ២.២ | មានខណ្ឌរាំង នៅបញ្ជរផ្តល់ព័ត៌មាន ចៀសវាងការទំនាក់ទំនងផ្ទាល់ រវាងភ្ញៀវ និងបុគ្គលិក ដោយមានសញ្ញាសម្គាល់គំនូសគម្លាតសុវត្ថិភាព និងមានប្រអប់ឧបករណ៍សង្គ្រោះបឋម (First Aids)។ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ៥* | |
| ២.៣ | មានកន្លែងភ្ញៀវរង់ចាំ ដោយរក្សាគម្លាតសុវត្ថិភាព ឬខណ្ឌរាំង និងមានផ្តល់អាល់កុល ដែលលាងដៃ ឬទឹកសម្លាប់មេរោគឱ្យបានគ្រប់គ្រាន់។ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ១០* | |
| | **សរុប** | **ពិន្ទុធ្វើបាន........** | **២០** | **0** |
| **៣** | **ការរៀបចំបរិវេណខាងក្នុងអគារក្លឹបកម្សាន្តរង្គសាល-ឌីស្កូតែក (សាលធំ)** | | **ចាំបាច់** | **ជម្រើស** |
| ៣.១ | កំណត់ចំនួនភ្ញៀវឱ្យសមាមាត្រទៅនឹងទំហំទីតាំងបរិវេណសាលធំ មិនឱ្យលើសចំនួនផ្ទុកជាអតិបរមានក្នុងទីតាំងបរិវេណសាលធំ ដោយរក្សាគម្លាតតាមការណែនាំរបស់ក្រសួងសុខាភិបាល។ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ១០* | |
| ៣.២ | មានកំណត់បរិវេណទីតាំងនីមួយៗដាច់ដោយឡែកពីគ្នា ដូចជា បរិវេណតុឈរ សាឡុង កន្លែងភ្ញៀវរាំលេងកម្សាន្ត កន្លែងប្រគុំតន្ត្រី កន្លែងឌីជេ និងបរិវេណបារ។ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ៥* | |
| ៣.៣ | ត្រូវរៀបចំតុ តុឈរ សាឡុងនីមួយៗឱ្យឆ្ងាតពីគ្នាដោយរក្សាគម្លាតសុវត្ថិភាព (១,៥ម៉ែត្រ)។ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ៥* | |
| ៣.៤ | ត្រូវរៀបចំកន្លែងភ្ញៀវរាំលេងកម្សាន្តឱ្យបានទំហំធំទូលាយ ដើម្បីរក្សាគម្លាតសុវត្ថិភាព។ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ៥* | |
| ៣.៥ | មានច្រកសុវត្ថិភាព (Exit) និងមានបំពង់ ឬឧបករណ៍ពន្លត់អគ្គីភ័យនៅតាមទីតាំងសំខាន់ៗក្នុងអាជីវកម្ម និងនៅតាមច្រករបៀង។ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ៥* | |
| ៣.៦ | ត្រូវធ្វើការសម្អាតអនាម័យ បាញ់អាល់កុល ឬទឹកសម្លាប់មេរោគលើសម្ភារៈប្រើប្រាស់ទាំងឡាយដូចជា តុ សាឡុង កៅអី និងសម្ភារៈឧបករណ៍ចាក់តន្ត្រីជាប្រចាំ និងមានផ្តល់អាល់កុល ដែលលាងដៃ ឬទឹកសម្លាប់មេរោគសម្រាប់ភ្ញៀវនៅគ្រប់តុ។ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ៥* | |
| ៣.៧ | មានបំពាក់តម្រងខ្យល់ប្រព័ន្ធម៉ាស៊ីនត្រជាក់ដែលមានប្រសិទ្ធិភាពខ្ពស់ក្នុងការចាប់យកអតិសុខុមប្រាណ និងបាក់តេរី និងរៀបចំឱ្យមានលំហូរខ្យល់ និងប្រព័ន្ធខ្យល់ចេញ-ចូល ដើម្បីធានាគុណភាពខ្យល់ ដោយត្រូវកំណត់ពេលវេលាផ្លាស់ប្តូរប្រព័ន្ធលំហូរខ្យល់ចេញ-ចូល ឱ្យបានទៀងទាត់។ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ៥* | |

| | | | | |
|---|---|---|---|---|
| ៣.៨ | ត្រូវរៀបចំជាបញ្ជីមុខម្ហូបតាមប្រព័ន្ធអេឡិចត្រូនិច ឬមធ្យោបាយណាមួយដែលចៀសវាងមិនឱ្យភ្ញៀវចាប់កាន់ ប៉ះពាល់បញ្ជីមុខម្ហូបបន្តបន្ទាប់គ្នា ឬបាញ់អាល់កុលសម្លាប់មេរោគលើបញ្ជីមុខម្ហូប មុន និងក្រោយពេលភ្ញៀវកាន់ ឬប៉ះពាល់។ | ☐ ធ្វើបានត្រឹមត្រូវ<br>☐ ធ្វើមិនបាន | | ៥ |
| ៣.៩ | ត្រូវបិទស្លាកសញ្ញា “ហាមជួញដូរ និងប្រើប្រាស់គ្រឿងញៀន” “ហាមជក់បារី” និងស្លាកសញ្ញាបំរាមផ្សេងៗទៀតនៅក្នុងអាជីវកម្មក្លឹបកម្សាន្តរង្គសាល-ឌីស្កូតែក។ | ☐ ធ្វើបានត្រឹមត្រូវ<br>☐ ធ្វើមិនបាន | ៥* | |
| ៣.១០ | លើកទឹកចិត្តឱ្យមានបំពាក់ចង្កៀងកាំរស្មី UVC ក្នុងក្លឹបកម្សាន្តរង្គសាល-ឌីស្កូតែក ដើម្បីសម្លាប់បាក់តេរី។ | ☐ ធ្វើបានត្រឹមត្រូវ<br>☐ ធ្វើមិនបាន | | ៥ |
| | **សរុប** | **ពិន្ទុធ្វើបាន.......** | **៤៥** | **១០** |
| **៤** | **ការរៀបចំបន្ទប់ទឹក** | | **ចាំបាច់** | **ជម្រើស** |
| ៤.១ | បន្ទប់ទឹកជាកន្លែងមានខ្យល់ចេញ-ចូល ឬមានឧបករណ៍សម្លាប់មេរោគក្នុងបរិយាកាស និងមានបុគ្គលិកប្រចាំការធ្វើការសម្អាត បាញ់ថ្នាំសម្លាប់មេរោគជាប្រចាំរៀងរាល់ពេលភ្ញៀវចាកចេញ។ | ☐ ធ្វើបានត្រឹមត្រូវ<br>☐ ធ្វើមិនបាន | ៥* | |
| ៤.២ | មានគំនូសសញ្ញារក្សាគម្លាតសុវត្ថិភាព នៅខាងមុខបន្ទប់ទឹក និងមានផ្តល់សាប៊ូ អាល់កុល ជែលលាងដៃ ឬទឹកសម្លាប់មេរោគ ក្រដាសអនាម័យ ឬម៉ាស៊ីនសម្ងួតដៃ នៅខាងមុខ និងក្នុងបន្ទប់ទឹក និងមានបិទផ្សាយខ្លឹមសារអំពីរបៀបលាងសម្អាតដៃឱ្យបានត្រឹមត្រូវ។ | ☐ ធ្វើបានត្រឹមត្រូវ<br>☐ ធ្វើមិនបាន | ៥* | |
| ៤.៣ | មានខណ្ឌរបាំងក្នុងបន្ទប់ទឹកសម្រាប់បុរស និងឡាបូលាងដៃ។ | ☐ ធ្វើបានត្រឹមត្រូវ<br>☐ ធ្វើមិនបាន | | ១០ |
| | **សរុប** | **ពិន្ទុធ្វើបាន.......** | **១០** | **១០** |
| **៥** | **ការគ្រប់គ្រងសុវត្ថិភាពភ្ញៀវ** | | **ចាំបាច់** | **ជម្រើស** |
| ៥.១ | ភ្ញៀវទាំងអស់ត្រូវបង្ហាញប័ណ្ណចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ចុះឈ្មោះក្នុងប្រព័ន្ធ QR CODE និងធ្វើតេស្តរហ័សអង់ទីហ្សែនកូវីដ-១៩ មុនអនុញ្ញាតឱ្យចូលក្នុងអាជីវកម្មក្លឹបកម្សាន្តរង្គសាល-ឌីស្កូតែក។ | ☐ ធ្វើបានត្រឹមត្រូវ<br>☐ ធ្វើមិនបាន | ១០* | |
| ៥.២ | លើកទឹកចិត្តភ្ញៀវឱ្យកក់ទុកមុន (Booking Service) តាមទូរស័ព្ទ ឬប្រព័ន្ធអនឡាញ ដើម្បីងាយស្រួលគ្រប់គ្រងចំនួនភ្ញៀវ។ | ☐ ធ្វើបានត្រឹមត្រូវ<br>☐ ធ្វើមិនបាន | | ១០ |
| ៥.៣ | ណែនាំភ្ញៀវមិនឱ្យមានការប្រមូលផ្តុំ ជួបជុំ និងចាប់ដៃស្វាគមន៍គ្នា ឬចាប់កាន់វត្ថុផ្សេងៗបន្តគ្នា។ | ☐ ធ្វើបានត្រឹមត្រូវ<br>☐ ធ្វើមិនបាន | ៥* | |
| | **សរុប** | **ពិន្ទុធ្វើបាន.......** | **១៥** | **១០** |

| | | | | |
|---|---|---|---|---|
| **៦** | **ការគ្រប់គ្រងសុវត្ថិភាពបុគ្គលិក** | | **ចាំបាច់** | **ជម្រើស** |
| ៦.១ | បុគ្គលិកទាំងអស់ត្រូវចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ឱ្យបានគ្រប់គ្នា និងគ្រប់ដូសតាមការណែនាំរបស់រាជរដ្ឋាភិបាល និងក្រសួងសុខាភិបាល។ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ១០* | |
| ៦.២ | បុគ្គលិកទាំងអស់ត្រូវពាក់ប័ណ្ណចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ឬឯកសារបញ្ជាក់ និងមានឯកសណ្ឋានត្រឹមត្រូវ សមរម្យ ពាក់ម៉ាស់ ស្រោមដៃ (និង/ឬរបាំងមុខ) ជាប់ជាប្រចាំ និងត្រូវលាងសម្អាតដៃជាមួយសាប៊ូ អាល់កុល ដែលលាងដៃ ទឹកសម្លាប់មេរោគឱ្យបានជាប់ជាប្រចាំក្រោយពេលបម្រើសេវាកម្ម ឬចាប់កាន់ប៉ះពាល់វត្ថុផ្សេងៗ។ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ៥* | |
| ៦.៣ | បុគ្គលិកទាំងអស់ ត្រូវទទួលបានការណែនាំ ឬឆ្លងកាត់វគ្គបណ្តុះបណ្តាលអំពីវិធានការការពារជំងឺកូវីដ-១៩ វគ្គបណ្តុះបណ្តាលស្តីពីបដិសណ្ឋារកិច្ចល្អ និងគុណភាពសេវាកម្មមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ។ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ៥* | |
| ៦.៤ | ត្រូវធ្វើតេស្តរហ័ស (Rapid Test) រៀងរាល់ពីរសប្តាហ៍ ឬមួយខែម្តង និងពេលមានការសង្ស័យ ឬពាក់ព័ន្ធជាមួយអ្នកផ្ទុកមេរោគកូវីដ-១៩។ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ១០* | |
| | **សរុប** | **ពិន្ទុធ្វើបាន.......** | **៣០** | **០** |
| **៧** | **យន្តការតាមដានត្រួតពិនិត្យការអនុវត្តរបស់អាជីវកម្មក្លឹបកម្សាន្ត រង្គសាល-ឌីស្កូតែក** | | **ចាំបាច់** | **ជម្រើស** |
| ៧.១ | លើកទឹកចិត្តឱ្យមានការរៀបចំទីតាំងអាជីវកម្មក្លឹបកម្សាន្តរង្គសាល-ឌីស្កូតែកស្ថិតក្នុងតំបន់ទីតាំងដែលរដ្ឋបាលរាជធានីខេត្តបានកំណត់ យោងតាមបទប្បញ្ញត្តិជាធរមាន (ប្រសិនបើរដ្ឋបាលរាជធានីខេត្តបានរៀបចំកំណត់តំបន់ទីតាំងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ Entertainment Zoning) ដែលសមស្របតាមស្ថានភាពទីតាំងភូមិសាស្ត្ររបស់រដ្ឋបាលរាជធានីខេត្តនីមួយៗ។ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | | ១០ |
| ៧.២ | អនុវត្តតាមវិធានការ និងសេចក្តីសម្រេចទាំងឡាយរបស់រាជរដ្ឋាភិបាល ដើម្បីចូលរួមទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ១០* | |
| ៧.៣ | រៀបចំផែនការសុវត្ថិភាពការពារជំងឺកូវីដ-១៩ (Covid-19 Safety Plan) របស់អាជីវកម្មផ្ទាល់ ដើម្បីចូលរួមទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | | ៥ |

| | | | | |
|---|---|---|---|---|
| ៧.៤ | បង្កលក្ខណៈងាយស្រួល និងតម្រូវឱ្យបុគ្គលិកទាំងអស់ចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ឱ្យបានគ្រប់គ្នា និងទិន្នន័យបុគ្គលិកបានចាក់វ៉ាក់សាំងទៅក្នុងប្រព័ន្ធចុះឈ្មោះ "ចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងវិស័យទេសចរណ៍"។ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ១០* | |
| ៧.៥ | មានការលើកទឹកចិត្តភ្ញៀវដែលបានចាក់វ៉ាក់សាំងគ្រប់ដូសតាមការណែនាំរបស់ក្រសួងសុខាភិបាល ដូចជាផ្តល់បណ្ណបញ្ចុះតម្លៃ ឬវត្ថុអនុស្សាវរីយ៍។ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | | ១០ |
| ៧.៦ | ឌីជេ (DJ) ត្រូវផ្សព្វផ្សាយក្រើនរំលឹកភ្ញៀវអំពីវិធានការការពារជំងឺកូវីដ-១៩ ឱ្យបានគ្រប់ពេល។ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | | ៥ |
| ៧.៧ | មានរៀបចំបន្ទប់ ឬកន្លែងដាច់ដោយឡែកសម្រាប់បុគ្គលិក ឬភ្ញៀវដែលសង្ស័យផ្ទុកមេរោគកូវីដ-១៩ រង់ចាំមុនពេលទទួលបានការព្យាបាល ឬការធ្វើចត្តាឡីស័ក និងមានគោលនយោបាយគាំទ្រ ឬអនុគ្រោះចំពោះបុគ្គលិកជាប់ចត្តាឡីស័ក ឬត្រូវសម្រាកព្យាបាលជំងឺកូវីដ-១៩។ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ៥* | |
| ៧.៨ | រៀបចំកន្លែងចម្អិនអាហារឱ្យមានអនាម័យ ស្របតាមគោលការណ៍ណែនាំស្តីពីស្តង់ដាសុវត្ថិភាពម្ហូបអាហាររបស់ក្រសួងសុខាភិបាល។ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ៥* | |
| | **សរុប** | **ពិន្ទុធ្វើបាន........** | **៣០** | **៣០** |

"វិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មក្លឹបកម្សាន្តរង្គសាលា-ឌីស្កូតែក" មាន **៣៥ ចំណុច ត្រូវវាយតម្លៃស្មើនឹង ២៣០ ពិន្ទុ** ក្នុងនោះអាជីវកម្មត្រូវអនុវត្តចំណុចចាំបាច់មាន **២៦** ចំណុច (**១៦៥** ពិន្ទុ) និងចំណុចដែលជាជម្រើសមាន **៩** ចំណុច (**៦៥** ពិន្ទុ) ។

អាជីវកម្មដែលទទួលបានលិខិតបញ្ជាក់ទទួលស្គាល់ជាអាជីវកម្មក្លឹបកម្សាន្តរង្គសាលា-ឌីស្កូតែកដែលបានអនុវត្តត្រឹមត្រូវតាម **"វិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មក្លឹបកម្សាន្តរង្គសាលា-ឌីស្កូតែក"** លុះត្រាតែ

- អាជីវកម្មអនុវត្តបានចាប់ពី ៨០% ឡើង នៃពិន្ទុសរុប និង
- បំពេញបានគ្រប់ចំណុចតម្រូវចាំបាច់ទាំង ២៦ ចំណុច។

លិខិតបញ្ជាក់នេះមានសុពលភាពរយៈពេលអតិបរមា **០១ (មួយ) ឆ្នាំ**។ លិខិតបញ្ជាក់នេះនឹងចាប់រាប់សុពលភាពចាប់ពីកាលបរិច្ឆេទសម្រេចផ្តល់លិខិតបញ្ជាក់ជូន រហូតដល់ការបញ្ចប់សុពលភាពនៅកាលបរិច្ឆេទដូចនឹងកាលបរិច្ឆេទបញ្ចប់សុពលភាពអាជ្ញាបណ្ណទេសចរណ៍ក្នុងឆ្នាំអនុវត្តតែមួយនោះ។

អាជីវកម្មដែលធ្លាប់ទទួលបានលិខិតបញ្ជាក់រួចហើយ នោះការបន្តស្នើសុំវាយតម្លៃ ដើម្បីទទួលបានលិខិតបញ្ជាក់ឆ្នាំអនុវត្តបន្ត គឺចាប់រាប់នៅពេលគាត់ស្នើសុំអាជ្ញាបណ្ណទេសចរណ៍។



ក្រសួង ទេសចរណ៍

# ឧបសម្ព័ន្ធ២

## នៃប្រកាសលេខ......១១៣ ទ.ក......ចុះថ្ងៃទី......១១......ខែ......វិច្ឆិកា......ឆ្នាំ២០២១......

## ស្ដីពី

## “ការដាក់ឱ្យអនុវត្តវិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មក្លឹបកម្សាន្តវង្គសាល-ឌីស្កូតែក”

## លិខិតបញ្ជាក់ទទួលស្គាល់អាជីវកម្មក្លឹបកម្សាន្តវង្គសាល-ឌីស្កូតែក ដែលអនុវត្តស្របតាមវិធានសុវត្ថិភាពទេសចរណ៍

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Logo
រដ្ឋបាលរាជធានី -ខេត្ត

រដ្ឋបាលរាជធានី ខេត្ត

លេខ:..................

មន្ទីរទេសចរណ៍រាជធានី ខេត្ត

### លិខិតបញ្ជាក់

ជូន

អាជីវកម្មឈ្មោះ..................................................................................................

អក្សរឡាតាំង..................................................................................................

ដែលបានអនុវត្តស្របតាមវិធានសុវត្ថិភាពទេសចរណ៍ សម្រាប់អាជីវកម្មក្លឹបកម្សាន្តវង្គសាល-ឌីស្កូតែក

សុពលភាពគិតចាប់ពីថ្ងៃទី..................................ដល់ថ្ងៃទី..................................

ទទួលបានពិន្ទុ..................

ថ្ងៃ..................ខែ..................ឆ្នាំ..................ស័ក ព.ស.២៥....

ថ្ងៃទី..................ខែ..................ឆ្នាំ..................

អភិបាលរាជធានី ខេត្ត

ប្រធានមន្ទីរទេសចរណ៍

QR-Code

..........................

..........................

*សម្គាល់: ការស្នើសុំអាជ្ញាបណ្ណទេសចរណ៍បន្ត និងត្រូវភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់នេះផងដែរ។

## ឧបសម្ព័ន្ធ៣

នៃប្រកាសលេខ........១៧៣ ទសក........ចុះថ្ងៃទី......១១......ខែ......វិច្ឆិកា......ឆ្នាំ២០......២១......

ស្តីពី

"ការដាក់ឱ្យអនុវត្តវិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មក្លឹបកម្សាន្តរង្គសាល-ឌីស្កូតែក"

## ឡាបិលបញ្ជាក់ទទួលស្គាល់អាជីវកម្មក្លឹបកម្សាន្តរង្គសាល-ឌីស្កូតែក
## សុវត្ថិភាពប្រឆាំងនឹងកូវីដ-១៩

